# ប្រកាស

# ស្តីពីក្របខណ្ឌសមត្ថកិច្ច

# របស់នាយកគ្រប់គ្រង

# ឧទ្យានជាតិ

# ២៥ មករា ១៩៩៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
ក្រសួងគ្រប់គ្រងបរិស្ថាន
លេខ: 115 ប.ស្ថ.

រាជធានីភ្នំពេញ ថ្ងៃទី 25 ខែ 01 ឆ្នាំ១៩៩6

# ប្រកាស

## ស្តីពី

## គ្របខ័ណ្ឌសមត្ថកិច្ចរបស់ នាយកគ្រប់គ្រងឧទ្យានជាតិ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស_រកត_១០៩៤_៨៣ ចុះថ្ងៃទី ២៤ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល,
- បានឃើញព្រះរាជក្រឹត្យរបស់ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ,
- យោងសេចក្តីត្រូវការចាំបាច់នៃការងារ,

## សំរេច

**ប្រការ១** : បង្កើតក្របខណ្ឌ និងសមត្ថកិច្ចគ្រប់គ្រងឧទ្យានជាតិ ដែលមានរចនាសម្ព័ន្ធ ដូចខាងក្រោម: ឧទ្យានជាតិនីមួយៗ ស្ថិតនៅក្រោមការដឹកនាំរបស់នាយកមួយរូបនិងនាយករងមួយរូបយ៉ាងតិច និងចែកចេញជាពីរផ្នែក : - ផ្នែកទទួលបន្ទុករដ្ឋបាល
- ផ្នែកទទួលបន្ទុកបច្ចេកទេស

**ប្រការ២** : នាយក នាយករងឧទ្យានជាតិ ក្នុងតំណែងមានឋានានុក្រម ស្មើនឹងប្រធាន អនុប្រធានការិយាល័យ ក្រសួងបរិស្ថាន ។

Nat.\Prokas1

លេខ ៤៨ វិថីទី ព្រះសីហនុ ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ 27894 / 015 914 055 ទូរសារ 855 23 27844

ប្រការ៣ : ក្របខណ្ឌ និងសមត្ថកិច្ចគ្រប់គ្រងឧទ្យានជាតិ ស្ថិតនៅក្រោមនិវាទនាយកដ្ឋានគ្រប់គ្រងឧទ្យានជាតិ និងប្រពន្ធ័ការពារធម្មជាតិ នៃក្រសួងបរិស្ថាន ។

ប្រការ៤ : កិច្ចការពាក់ពន្ធ័នឹងសមត្ថកិច្ចអាជ្ញាធរខេត្ត ក្រុង ត្រូវធ្វើឡើងតាមរយៈមន្ទីរបរិស្ថានប្រចាំខេត្ត-ក្រុង ។

ប្រការ៥ : តួនាទី និងភារកិច្ចរបស់នាយកឧទ្យានជាតិ រួមមាន:

៥.១- ដឹកនាំការងារ លើកគំរោង ធ្វើផែនការ សិក្សាស្រាវជ្រាវ ការពារអភិរក្ស និងអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាពឧទ្យានជាតិ ។

៥.២- រក្សាការពារ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងតំបន់ឧទ្យានជាតិ.

៥.៣ ក្នុងក្របខណ្ឌនៃប្រការ ៣ នាយកឧទ្យានជាតិ ទទួលសិទ្ធិធ្វើសហប្រតិបត្តិការជាទ្វេភាគី ឬពហុភាគីជាមួយអង្គការជាតិ និងអន្តរជាតិក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកទេស និងទទួលជំនួយសំភារៈ ថវិកាសំរាប់ធ្វើការអភិរក្ស សិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ឧទ្យានជាតិ ។

៥.៤- ធ្វើអន្តរាគមជាមួយស្ថាប័នពាក់ពន្ធ័ និងរដ្ឋអំណាចមូលដ្ឋាន ក្នុងការការពារបូរណៈភាពឧទ្យានជាតិ ។

ប្រការ៦ : អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងឧទ្យានជាតិ និងប្រពន្ធ័ការពារធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត-ក្រុង នាយកឧទ្យានជាតិនីមួយៗ ត្រូវមានភារកិច្ចអនុវត្តសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បណ្ឌិត ម៉ុក-ម៉ារ៉េត

ចំលងថ្វាយនិងជូន:

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងទេសចរណ៍
- ក្រសួងការពារជាតិ
- ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ
- អភិបាលខេត្ត-ក្រុងពាក់ពន្ធ័
- មន្ទីរបរិស្ថានខេត្ត-ក្រុងពាក់ពន្ធ័
- ដូចប្រការ៦ "ដើម្បីសហការអនុវត្ត"
- កាលប្បវត្តិ-ឯកសារ.

Nat.\Prokas1